ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ៣៣ អយក.អក

| ក្រុមការងារ ក្រុង ស្រុក ខណ្ឌ | |
|---|---|
| ចូល | លេខ : ៨០៥ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១២ |
| បញ្ជូន : | |

# លិខិតអម

**គោរពផ្ញើជូន ៖ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

| ល.រ | កម្មវត្ថុឯកសារ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | ប្រកាសលេខ២៤៦៦ អយក.ប្រក ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការផ្ទេរប្រតិភូកម្មមុខងារ និងភារកិច្ច ការងារអប់រំ យុវជន និង កីឡាជូនក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូល តែមួយ | ០១ | |
| ២ | សេចក្តីណែនាំលេខ១៩ អយក.សណន ចុះថ្ងៃទី១៨ ខែមិថុនាឆ្នាំ២០១២ ស្តីពីការអនុវត្តខ្លឹមសារប្រកាស ប្រកាស ២៤៦៦ អយក.ប្រក ស្តីពីការផ្ទេរប្រតិភូកម្មមុខងារ និងភារកិច្ច ការងារអប់រំ យុវជន និងកីឡាជូនក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ | ០១ | |
| ៣ | ឧបសម្ព័ន្ធទី៥ តារាងកម្រៃសេវាកម្មលើមុខងារ ភារកិច្ចវិស័យអប់រំ យុវជន និងកីឡា ផ្ទេរ ប្រតិភូកម្មជូនក្រុង ស្រុកគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ | ០១ | |

- បញ្ឈប់បញ្ជីត្រឹមលេខរៀងទី ០៣ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២
**តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គនាយក**

**ថោង បូរ៉ាន់**

អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៥៦ / ៤២៦ ៥៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ [illegible] អយក.

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ច ការងារអប់រំ យុវជន និងកីឡា ជូនក្រុង ស្រុក ខណ្ឌ គោលដៅ នៃការិយាល័យច្រកចេញចូលតែមួយ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/រកម/៩៤ ចុះថ្ងៃ២០ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសេចក្តីសម្រេចលេខ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ

## សម្រេច

### ប្រការ ១.–

ត្រូវបានធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចការងារអប់រំ យុវជន និងកីឡា ជូនក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ ក្នុងក្របខ័ណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាត៖


អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ [illegible]
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

- បើកសាលា ឬ ថ្នាក់មត្តេយ្យសិក្សាឯកជន
- បើកថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង១ឆ្នាំ
- បើកក្លឹបហាត់ប្រាណ
- បើកអាជីវកម្មលក់សម្ភារកីឡា

**ប្រការ ២.** -

មន្ត្រីទទួលបន្ទុកការងារបច្ចេកទេសអប់រំ យុវជន និងកីឡា ត្រូវរៀបចំគំរូបែបបទផ្សេងៗ រួមទាំងឯកសារពាក់ព័ន្ធសម្រាប់ការផ្តល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតទៅតាមការកំណត់ដូចមានចែងនៅក្នុងប្រការ១។

**ប្រការ ៣.** -

ការអនុវត្តលើគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការផ្តល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតក្នុងវិស័យអប់រំ យុវជន និងកីឡា ត្រូវកំណត់ដោយសេចក្តីណែនាំដោយឡែករបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ៤.** -

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តគោលដៅ ត្រូវជំរុញ និងចូលរួមគាំទ្រការអនុវត្តការងារនេះ។

ក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវធ្វើរបាយការណ៍អំពីស្ថិតិនៃការផ្តល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតសេវាកម្មក្នុងវិស័យអប់រំ យុវជន និងកីឡាជារៀងរាល់ខែមកក្រសួងអប់រំ យុវជន និងកីឡាតាមរយៈមន្ទីរអប់រំ យុវជន និងកីឡា។

**ប្រការ ៥.** -

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦.** -

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានអប់រំកុមារតូច ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ប្រធាននាយកដ្ឋានអប់រំកាយ និងកីឡា ប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា

ប្រធាននាយកដ្ឋាននីតិកម្ម អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត គោលដៅត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ[illegible] ឆ្នាំ២០១២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

អ៊ឹម_សេធី

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- រដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធ
- សាលារាជធានី ខេត្តគោលដៅ
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា

*«ដើម្បីជ្រាបជាព័ត៌មាន»*

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ
- ដូចមានចែងក្នុងប្រការ ២ និង ៦

*«ដើម្បីអនុវត្ត»*

- ឯកសារ-កាលប្បវត្តិ នា.នីតិកម្ម

ឧបសម្ព័ន្ធទី ៥

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

## តារាងកម្រៃសេវាកម្មលើមុខងារ តារកិច្ចវិស័យអប់រំ យុវជន និងកីឡា ធ្វើប្រតិភូកម្មជូនក្រុង ស្រុក គោលដៅ នៃការិយាល័យច្រកចេញចូលតែមួយ

| ល.រ | រាយមុខសេវាកម្ម | កម្រៃសេវាកម្ម | | | | | សុពលភាព | ប្រភេទ |
|---|---|---|---|---|---|---|---|---|
| | | ពាក្យសុំ | តែមប្រ៊ | សេវាប្រតិបត្តិ | តម្លៃបង់ជូនរដ្ឋ | សរុប | | |
| ១ | អាជ្ញាប័ណ្ណបើកសាលា ឬ ថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) | ១.០០០៛ | ២.០០០៛ | ១១០.០០០៛ | ៩០.០០០៛ | ២០៣.០០០៛ | ០៥ ឆ្នាំ | អាជ្ញាប័ណ្ណ |
| | ការធ្វើសុពលភាពឡើងវិញ (១) | ១.០០០៛ | ២.០០០៛ | ៥.៥០០០៛ | ៩៥.០០០៛ | ១០៣.០០០៛ | ០៥ ឆ្នាំ | |
| ២ | អាជ្ញាប័ណ្ណបើកសាលា ឬ ថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) | ១.០០០៛ | ២.០០០៛ | ២២០.០០០៛ | ១៨០.០០០៛ | ៤០៣.០០០៛ | ០៥ ឆ្នាំ | អាជ្ញាប័ណ្ណ |
| | ការធ្វើសុពលភាពឡើងវិញ (២) | ១.០០០៛ | ២.០០០៛ | ១១.០០០០៛ | ៩០.០០០៛ | ២០៣.០០០៛ | ០៥ ឆ្នាំ | |
| ៣ | អាជ្ញាប័ណ្ណបើកថ្នាក់បណ្ដុះបណ្ដាលជំនាញ និងភាសា បរទេសវគ្គខ្លីរតិចជាង១ឆ្នាំ | ១.០០០៛ | ២.០០០៛ | ១១០.០០០៛ | ៩០.០០០៛ | ២០៣.០០០៛ | ០៥ ឆ្នាំ | អាជ្ញាប័ណ្ណ |
| | ការធ្វើសុពលភាពឡើងវិញ (៣) | ១.០០០៛ | ២.០០០៛ | ៥.៥០០០៛ | ៩៥.០០០៛ | ១០៣.០០០៛ | ០៥ ឆ្នាំ | |
| ៤ | លិខិតអនុញ្ញាតបង្កើតក្លឹបហាត់ប្រាណ | ១.០០០៛ | ២.០០០៛ | ១១០.០០០៛ | ៩០.០០០៛ | ២០៣.០០០៛ | ០១ ឆ្នាំ | លិខិតអនុញ្ញាត |
| | ការធ្វើសុពលភាពឡើងវិញ (៤) | ១.០០០៛ | ២.០០០៛ | ៥.៥០០០៛ | ៩៥.០០០៛ | ១០៣.០០០៛ | ០១ ឆ្នាំ | |
| ៥ | លិខិតអនុញ្ញាតអាជីវកម្មលក់សម្ភារកីឡា | ១.០០០៛ | ២.០០០៛ | ១១០.០០០៛ | ៩០.០០០៛ | ២០៣.០០០៛ | ០១ ឆ្នាំ | លិខិតអនុញ្ញាត |
| | ការធ្វើសុពលភាពឡើងវិញ (៥) | ១.០០០៛ | ២.០០០៛ | ៥.៥០០០៛ | ៩៥.០០០៛ | ១០៣.០០០៛ | ០១ ឆ្នាំ | |

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១២

ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ ១៩ អយក. សាជក

# សេចក្តីណែនាំ

## ការអនុវត្តខ្លឹមសារប្រកាសលេខ២៤៦៦ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១២ ស្តីពីការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ច ការងារអប់រំ យុវជន និងកីឡា ជូនក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ

ផ្អែកលើខ្លឹមសារសេចក្តីសម្រេចលេខ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅតាមក្រុង ស្រុក ខណ្ឌគោលដៅ ក្នុងគោលបំណងជំរុញឱ្យមានដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងសម្រេចបាននូវគោលនយោបាយកំណែទម្រង់នានា ពិសេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ឆ្លើយតបនឹងខ្លឹមសារខាងលើ រាជរដ្ឋាភិបាលតាមរយៈក្រសួងមហាផ្ទៃ បានអនុវត្តការងារនេះយ៉ាងសស្រាក់សស្រាំ និងបានតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដែលមានសេវាបម្រើប្រជាពលរដ្ឋធ្វើប្រតិភូកម្មមុខងាររបស់ខ្លួនមួយចំនួនជូនក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ។ ជាការឆ្លើយតប ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវប្រកាសលេខ ២៤៦៦ ចុះថ្ងៃទី ១៤ខែមិថុនាឆ្នាំ២០១២ស្តីពីការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ច ការងារអប់រំ យុវជន និងកីឡាជូនក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ។ ដើម្បីធានាបាននូវប្រសិទ្ធភាព និងលក្ខខណ្ឌចាំបាច់នៃការងារគ្រប់គ្រង និងការអនុវត្តប្រកាសនេះ ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការណែនាំដូចខាងក្រោម៖

### I. អំពីបែបបទនៃការស្នើសុំប្រកបអាជីវកម្ម

១. ការបើកសាលា ឬ ថ្នាក់មត្តេយ្យសិក្សាឯកជន និងការបើកថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង១ឆ្នាំ

អតិថិជនដែលមានបំណងបើកសាលា ឬ ថ្នាក់មត្តេយ្យសិក្សាឯកជន និងបើកថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង១ឆ្នាំត្រូវបំពេញទម្រង់បែបបទដូចខាងក្រោម៖

- ពាក្យស្នើសុំ(មានបិទតែមប្រិ៍)........................................................ ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ចម្លង ឬ លិខិតឆ្លងដែន ឬ ទិដ្ឋាការ )....... ០១ច្បាប់

អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ [illegible]
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

- កិច្ចសន្យា............................................................................................ ០១ច្បាប់
- ប្លង់បង្ហាញទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ.................................................. ០១ច្បាប់
- រូបថត ទំហំ ៤ x ៦ ............................................................................ ០៣សន្លឹក

ចំពោះការស្នើសុំបន្ត ទម្រង់បែបបទនេះត្រូវកាត់បន្ថយដោយគ្រាន់តែបំពេញនូវ៖

- ពាក្យស្នើសុំ(មានបិទតែមប្រ៍)........................................ ............. ០១ច្បាប់
- កិច្ចសន្យាបន្ត......................................................................... ០១ច្បាប់
- អាជ្ញាប័ណ្ណចាស់....................................................................... ០១ច្បាប់
- រូបថត ទំហំ ៤ x ៦ ............................................................................ ០៣សន្លឹក

តម្រូវការឯកសារសម្រាប់ការស្នើសុំ៖

១-បើកសាលា ឬ ថ្នាក់មត្តេយ្យសិក្សាឯកជន

២-បើកថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង១ឆ្នាំ

នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និង/ឬ រូបវន្តបុគ្គលមានសិទ្ធិស្នើសុំបើកសាលា ឬ ថ្នាក់មត្តេយ្យសិក្សាឯកជន ថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង១ឆ្នាំ ដោយភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដែលមានដូចជា៖

- លិខិតស្នើសុំបើកសាលា ឬ ថ្នាក់ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីគោលបំណង និងកម្រិតសិក្សានីមួយៗ
- ឯកសារអភិបាលកិច្ច និងការគ្រប់គ្រង ដោយភ្ជាប់ជាមួយនូវរចនាសម្ព័ន្ធគ្រប់គ្រង និងបទបញ្ជាផ្ទៃក្នុង វិសាលភាព និងលក្ខន្តិកៈរបស់សាលា ឬ ថ្នាក់
- ប្រវត្តិរូបរបស់នាយក/នាយិកា នាយករង/នាយិការង និងប្រធានការិយាល័យ ឬ ផ្នែកដោយបញ្ជាក់ពីកម្រិតសញ្ញាបត្រ បទពិសោធការងារ និងភ្ជាប់មកជាមួយសញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កម្មវិធីសិក្សាលម្អិតស្របតាមកម្រិតដែលស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា
- របាយការណ៍ ស្តីពីទីតាំង ផ្ទៃដី អគារ និងហេដ្ឋារចនាសម្ព័ន្ធស្របតាមស្តង់ដា
- របាយការណ៍ ស្តីពីមូលដ្ឋានសម្ភារដូចជា តុ កៅអី ក្តារខៀន សៀវភៅបញ្ជីសម្ភារឧបទ្ទេស និងឧបករណ៍ផ្សេងទៀតស្របតាមនិយាមគរុកោសល្យ
- បុគ្គលិកអប់រំ គ្រូមត្តេយ្យសិក្សាត្រូវទទួលការបណ្តុះបណ្តាលជំនាញច្បាស់លាស់
- បញ្ជីរាយនាមបុគ្គលិក/គ្រូបង្រៀនដោយបញ្ជាក់ពីកម្រិតសញ្ញាបត្រមុខជំនាញបទពិសោធការងារ និងភ្ជាប់មកជាមួយនូវប្រវត្តិរូប សញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

Daly ធី

- ចំពោះអ្នកគ្រប់គ្រង និងបុគ្គលិកជាជនបរទេសត្រូវមានសិទ្ធិរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២. ការបើកក្លឹបហាត់ប្រាណ និងការបើកអាជីវកម្មលក់សម្ភារកីឡា

អតិថិជនដែលមានបំណងបើកក្លឹបហាត់ប្រាណ អាជីវកម្មលក់សម្ភារកីឡាត្រូវបំពេញទម្រង់បែបបទដូចខាងក្រោម៖

២.១. បើកក្លឹបហាត់ប្រាណ

- ពាក្យស្នើសុំ(មានបិទតែមប្រ៊ី)........................................ ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ចម្លង ឬ លិខិតឆ្លងដែន ឬ ទិដ្ឋាការ )....... ០១ច្បាប់
- កិច្ចសន្យា........................................ ០១ច្បាប់
- ប្លង់បង្ហាញទីតាំងនិងហេដ្ឋារចនាសម្ព័ន្ធ........................................ ០១ច្បាប់
- រូបថត ទំហំ ៤ x ៦ ........................................ ០៣សន្លឹក

ចំពោះការស្នើសុំបន្ត ទម្រង់បែបបទនេះត្រូវកាត់បន្ថយដោយគ្រាន់តែបំពេញនូវ៖

- ពាក្យស្នើសុំ(មានបិទតែមប្រ៊ី)........................................ ០១ច្បាប់
- កិច្ចសន្យាបន្ត........................................ ០១ច្បាប់
- អាជ្ញាប័ណ្ណចាស់........................................ ០១ច្បាប់
- រូបថត ទំហំ ៤ x ៦ ........................................ ០៣សន្លឹក

២.២. បើកអាជីវកម្មលក់សម្ភារកីឡា

- ពាក្យស្នើសុំ(មានបិទតែមប្រ៊ី)........................................ ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ចម្លង ឬ លិខិតឆ្លងដែន ឬ ទិដ្ឋាការ )....... ០១ច្បាប់
- កិច្ចសន្យា........................................ ០១ច្បាប់
- ប្លង់បង្ហាញទីតាំងអាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធ........................................ ០១ច្បាប់
- រូបថត ទំហំ ៤ x ៦ ........................................ ០៣សន្លឹក

ចំពោះការស្នើសុំបន្ត ទម្រង់បែបបទនេះត្រូវកាត់បន្ថយដោយគ្រាន់តែបំពេញនូវ៖

- ពាក្យស្នើសុំ(មានបិទតែមប្រ៊ី)........................................ ០១ច្បាប់
- កិច្ចសន្យាបន្ត........................................ ០១ច្បាប់
- អាជ្ញាប័ណ្ណចាស់........................................ ០១ច្បាប់
- រូបថត ទំហំ ៤ x ៦ ........................................ ០៣សន្លឹក

តម្រូវការឯកសារសម្រាប់ការស្នើសុំ៖

១-បើកក្លឹបហាត់ប្រាណ

២-បើកអាជីវកម្មលក់សម្ភារកីឡា

Dolu ថ្រ

នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និង/ឬ រូបវន្តបុគ្គលមានសិទ្ធិស្នើសុំបើកក្លឹបហាត់ប្រាណ អាជីវកម្មលក់សម្ភារកីឡា ដោយភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា៖

- លិខិតស្នើសុំបើកក្លឹបហាត់ប្រាណ អាជីវកម្មលក់សម្ភារកីឡា ដោយបញ្ជាក់ពីគោលបំណងឱ្យច្បាស់លាស់
- ឯកសារអភិបាលកិច្ច និងការគ្រប់គ្រង ដោយភ្ជាប់ជាមួយនូវរចនាសម្ព័ន្ធគ្រប់គ្រង និងបទបញ្ជាផ្ទៃក្នុង វិសាលភាព និងលក្ខន្តិកៈរបស់ក្លឹប
- ប្រវត្តិរូបរបស់អ្នកគ្រប់គ្រងក្លឹប ឬ ម្ចាស់អាជីវកម្មដោយបញ្ជាក់ពីកម្រិតសញ្ញាបត្រ បទពិសោធការងារ និងភ្ជាប់មកជាមួយសញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- បញ្ជីរាយនាមគណៈកម្មការគ្រប់គ្រងក្លឹប
- បញ្ជីរាយនាមគ្រូបង្វឹក និងកីឡាករ កីឡាការិនី
- បញ្ជីរាយនាមអ្នកជំនាញ និងប្រវត្តិរូប
- លក្ខន្តិកៈរបស់ក្លឹប
- របាយការណ៍ ស្តីពីទីតាំង ផ្ទៃដី អគារ និងហេដ្ឋារចនាសម្ព័ន្ធឲ្យស្របតាមស្តង់ដា
- របាយការណ៍ ស្តីពីមូលដ្ឋានសម្ភារកីឡារបស់ក្លឹប
- បញ្ជីរាយនាមបុគ្គលិកដោយបញ្ជាក់ពីកម្រិតសញ្ញាបត្រមុខជំនាញបទពិសោធការងារ និងភ្ជាប់ជាមួយនូវប្រវត្តិរូប សញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- ចំពោះអ្នកគ្រប់គ្រង និងបុគ្គលិកជាជនបរទេសត្រូវមានសិទ្ធិរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា។

## II-សោហ៊ុយលើសេវាកម្ម

សោហ៊ុយលើសេវាកម្មសម្រាប់ការចេញអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតរបស់ក្រុង ស្រុក ខណ្ឌ គោលដៅ មាននៅក្នុងឧបសម្ព័ន្ធទី៥។ ចំពោះសោហ៊ុយលើសេវាកម្មទាំងនេះ សាលាក្រុង ស្រុក ខណ្ឌ គោលដៅ ត្រូវអនុវត្តឱ្យមានតម្លាភាព ដោយមានការកត់ត្រាក្នុងបញ្ជីច្បាស់លាស់ តាមគោលការណ៍ដែលបានកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច។

## III-វិធីបែបបទនៃការផ្តល់លិខិតអនុញ្ញាត

- ការដាក់សំណុំឯកសារនៃពាក្យស្នើសុំ និងការធ្វើទំនាក់ទំនងទទួលព័ត៌មានពាក់ព័ន្ធ ត្រូវប្រព្រឹត្តទៅនៅការិយាល័យច្រកចេញចូលតែមួយនៃផ្នែកជួរមុខ
- ការិយាល័យច្រកចេញចូលតែមួយត្រូវទទួលរាល់សំណុំឯកសារ នៃពាក្យសុំដែលមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមបញ្ជីត្រួតពិនិត្យ។ ការទទួលពាក្យស្នើសុំត្រូវចុះកាលបរិច្ឆេទ និងចេញបង្កាន់ដៃទទួលពាក្យ

 Daly ក្រី

- ការត្រួតពិនិត្យសំណុំឯកសារនៃពាក្យស្នើសុំអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតរបស់សាលាក្រុង ស្រុក ខណ្ឌ គោលដៅមានរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការងារ។ រយៈពេលត្រួតពិនិត្យរាល់សំណុំឯកសារនៃពាក្យសុំត្រូវគិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារ នៃពាក្យស្នើសុំ
- រាល់ការសម្រេចលើពាក្យស្នើសុំអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតនានា ត្រូវអនុវត្តតាមបែបបទរដ្ឋបាលរបស់សាលា ក្រុង ស្រុក ខណ្ឌគោលដៅ
- រាល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតដែលផ្តល់ដោយសាលាក្រុង ស្រុក ខណ្ឌគោលដៅ និងឯកសារពាក់ព័ន្ធនានា សាលាក្រុង ស្រុក ខណ្ឌគោលដៅត្រូវបញ្ជូនច្បាប់ចម្លងឯកសារទាំងនោះចំនួនមួយច្បាប់ទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

IV-**ការត្រួតពិនិត្យតាមដាន**

ការពិនិត្យតាមដានលើដំណើរការរបស់សាលា ឬ ថ្នាក់មត្តេយ្យសិក្សាឯកជន ថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង១ឆ្នាំ ក្លឹបហាត់ប្រាណ និងអាជីវកម្មលក់សម្ភារកីឡា គឺជាសមត្ថកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡា និងក្រសួងអប់រំ យុវជន និងកីឡា ដោយមានការសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ដើម្បីចាត់វិធានការដាក់ស្តែងចំពោះរាល់សកម្មភាពមិនប្រក្រតី។

សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ចាត់ចែងអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១...៤...ខែ...ឧសភា... ឆ្នាំ២០១២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម សុធី**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- រដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធ
- សាលារាជធានី ខេត្តគោលដៅ
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា

*«ដើម្បីជ្រាបជាព័ត៌មាន»*

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ
- ដូចមានចែងក្នុងប្រការ ២ និង ៦

*«ដើម្បីអនុវត្ត»*

- ឯកសារ-កាលប្បវត្តិ នា.និតិកម្ម